**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# តំណាងកម្មករនិយោជិត និងសហជីពនៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី២១ ខែធ្នូ ឆ្នាំ២០២០ រវាងសហជីពនិយោជិតទេសចរណ៍អាស៊ាននៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់(ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិល រ៉ូយ៉ាល់ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Hotel Le Royal កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃកូរ៉ូណាវីរុស ទូទាំងពិភពលោកបាននាំមកនូវ ការបញ្ឈប់ការធ្វើដំណើរអន្តរជាតិទាំងអស់ ហេតុដូចនេះហើយ សណ្ឋាគារកំពុងតែជួបប្រទះនូវកម្រិតអាជីវកម្មដែលមិនស្ថិតស្ថេរ។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចា និងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣២នាក់ (ស្រី ១០នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៤១នាក់ (ស្រី ៨៧នាក់) រយៈពេល ១៦ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ គូភាគីបានព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ននឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោលរបស់ពួកគេ។
- និយោជិតនឹងមិនទទួលបានប្រាក់ធានានុគ្រោះក្នុងពេលព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ន។
- ការព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ននឹងត្រូវបានផ្ដល់អាទិភាពដោយផ្អែកលើអតីតភាពការងាររបស់និយោជិត តាមផ្នែកនីមួយៗ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នឹងបន្តជម្មតា
- អតីតភាពការងារនឹងមិនត្រូវបានប៉ះពាល់

គូភាគីព្រមព្រៀងដោយផ្តិតមេដៃខាងក្រោមនេះ៖

ភាគី តំណាងកម្មករនិយោជិត និងសហជីព

ប៉ាល់ ពិសិដ្ឋ
ប្រធាន

ប៊ុន រឿន
អនុប្រធាន

សូ សារ៉ុន
លេខាធិការ

ភាគីនិយោជក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២០
ហត្ថលេខា និងត្រា
នាយកសណ្ឋាគារ

Raffles Royal Hotel Pte., Ltd.

Oliver Dudler